# លទ្ធផលការងារ បញ្ហាប្រឈម និងទិសដៅការងារ ឆ្នាំ២០១៧ របស់មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត

**ដោយ៖ ឯកឧត្តម យូ ស៊ុនឡុង**

រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ

# មាតិកា

១) លទ្ធផលសំខាន់ៗនៃការអនុវត្តការងារឆ្នាំ២០១៦

២) បញ្ហាប្រឈម

៣) សំណូមពររបស់មន្ទីរមុខងារសាធារណៈ

៤) ទិសដៅការងារបន្តសម្រាប់ឆ្នាំ២០១៧

សេចក្តីសន្និដ្ឋាន

ឧបសម្ព័ន្ធនៃប្រកាសលេខ ១៩ ៧៩ មក.ឧក

ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៤

## អង្គការលេខរបស់មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត

**មន្ទីរមុខងារសាធារណៈ**
**រាជធានី ខេត្ត**

- **ការិយាល័យ** **រដ្ឋបាលនិងហិរញ្ញវត្ថុ**
- **ការិយាល័យ** **ក្របខណ្ឌនិងបណ្ដុះបណ្ដាល**
- **ការិយាល័យ** **ត្រួតពិនិត្យរដ្ឋបាលនិងបៀវត្ស**

# ១) លទ្ធផលសំខាន់ៗនៃការអនុវត្តការងារឆ្នាំ២០១៦
## ១.១ ការងាររដ្ឋបាលនិងហិរញ្ញវត្ថុ

- ចូលរួមក្នុងកិច្ចការសង្គម បុណ្យជាតិ អន្តរជាតិ និងព្រឹត្តិការណ៍ផ្សេងៗ
- ចូលរួមកិច្ចប្រជុំ សិក្ខាសាលាផ្សព្វផ្សាយ ការបណ្តុះបណ្តាល និងវេទិកាសាធារណៈ
- សហការ និងសម្របសម្រួលជាមួយនឹងមន្ទីរ អង្គភាពនានាជុំវិញខេត្ត និងគណៈអភិបាលក្នុងគោលដៅបំពេញមុខងារនិងភារកិច្ចឱ្យមានប្រសិទ្ធភាព
- ចំនួនមន្ត្រីមន្ទីរមុខងារសាធារណៈសរុប ៣២៣នាក់ (ស្រី១០៨នាក់) និងមន្ត្រីជាប់កិច្ចសន្យាចំនួន ១២៥នាក់ ដែលក្នុងនោះ៖
  - ប្រធានមន្ទីរសរុបចំនួន២៥នាក់ (ស្រី០១នាក់)
  - អនុប្រធានមន្ទីរសរុបចំនួន ៤៨នាក់ (ស្រី១២នាក់)
  - ប្រធានការិយាល័យសរុបចំនួន ៦០នាក់(ស្រី១១នាក់)
  - អនុប្រធានការិយាល័យសរុបចំនួន ៣៤នាក់ (ស្រី១៤នាក់
  - មន្ត្រី សរុបចំនួន ១៥៦នាក់ (ស្រី៦០នាក់)

## ១.១ ការងាររដ្ឋបាលនិងហិរញ្ញវត្ថុ(បន្ត)

- បានរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋនិងធ្វើបច្ចុប្បន្នភាពជាប្រចាំ
- រៀបចំផែនការយុទ្ធសាស្ត្រថវិកាតាមកម្មវិធីបានទាន់ពេលវេលា
- បានអនុវត្តថវិកាស្របតាមគោលការណ៍និងនីតិវិធីហិរញ្ញវត្ថុមានជាអាទិ៍៖ ធ្វើជានាចំណាយគ្រឿងសង្ហារឹម ម៉ូតូ សម្ភារៈបច្ចេកទេស សម្ភារៈការិយាល័យ និងប្រេងសាំង

## ១.២ ការងារក្របខណ្ឌ និងបណ្តុះបណ្តាល

- បានចូលរួមរៀបចំប្រលងប្រជែងមន្ត្រីជាប់កិច្ចសន្យានិងមន្ត្រីស្ម័គ្រចិត្ត ឱ្យចូលបម្រើការនៅក្នុងក្រសួងធម្មការ និងសាសនា
- បានចូលរួមសហការរៀបចំផែនការជ្រើសរើសក្របខណ្ឌមន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យាបុគ្គលិកអណ្តែត និងឧទ្យានុរក្សរបស់ក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ ២០១៦
- បានចូលរួមសហការធ្វើគម្រោងផែនការប្រើប្រាស់មន្ត្រីក្របខណ្ឌថ្មី មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែតឆ្នាំ២០១៧
- បានចូលរួមក្នុងសិក្ខាសាលាផ្សព្វផ្សាយនិងដាក់ឱ្យអនុវត្តព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការ
- បានបញ្ជូនមន្ត្រីរាជការថ្នាក់ប្រធានការិយាល័យមកចូលរួមវគ្គបណ្តុះបណ្តាលតម្រង់ទិសនិងអភិវឌ្ឍសមត្ថភាពដែលរៀបចំឡើងដោយក្រសួងមុខងារសាធារណៈ

# ១.២ ការចារក្របខណ្ឌ និងបណ្តុះបណ្តាល(បន្ត)

- បានធ្វើរបាយការណ៍អំពីការប្រើប្រាស់ចំនួនមន្ត្រីរាជការក្របខណ្ឌ និងចំនួនមន្ត្រីជាប់កិច្ចសន្យារបស់មន្ទីរជំនាញ និងអង្គភាពនានាជុំវិញរាជធានី ខេត្ត
- បានរៀបចំឯកសារដើម្បីបញ្ចូល ប្រាក់បៀវត្សក្នុងគណនីជូនមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិរួចរាល់
- មន្ទីរមុខងារសាធារណៈមួយចំនួនបានសហការជាមួយក្រសួង បើកវគ្គផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈមានជាអាទិ៍៖ មន្ទីរមុខងារសាធារណៈខេត្តប៉ៃលិន ខេត្តបាត់ដំបង ខេត្តស្វាយរៀង ខេត្តកំពង់ឆ្នាំង រាជធានីភ្នំពេញ ខេត្តក្រចេះ កំពង់ចាម និងខេត្តកំពង់ធំ។
- មន្ទីរមុខងារសាធារណៈខេត្តស្ទឹងត្រែង បានធ្វើការបណ្តុះបណ្តាលពាក់ព័ន្ធនឹងនីតិវិធីក្នុងការស្រង់ទិន្នន័យមន្ត្រីរាជការស៊ីវិលក្រោយពីសមាហរណកម្មក្របខណ្ឌ
- បានសហការណ៍ជាមួយក្រុមការងារក្រសួងក្នុងការរៀបចំ ពិពណ៌សមិទ្ធផលនានា និងបានចែកសៀវភៅបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ ជូនដល់ភ្ញៀវជាតិ និងអន្តរជាតិដែលអញ្ជើញមកទស្សនាខេត្តសៀមរាប។

## ១.២ ការងារក្របខណ្ឌ និងបណ្តុះបណ្តាល(បន្ត)

- មន្ទីរមុខងារសាធារណៈមួយចំនួនបានចុះត្រួតពិនិត្យតាមដាន ការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល តាមមន្ទីរជំនាញជុំវិញខេត្ត
- បានផ្សព្វផ្សាយស្តីពីការរៀបចំចងក្រងការពិពណ៌នាមុខតំណែងគ្រប់គ្រង ក្រសួងស្ថាប័នថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ដល់មន្ត្រីរាជការស៊ីវិល នៅតាមបណ្តាមន្ទីរ សរុប ២៤ មន្ទីរ និង ០៧ ក្រុង/ស្រុក បានចំនួន ០១ លើក
- បានពិនិត្យ និង ផ្តល់ទិដ្ឋាការសំណើសុំប្រើប្រាស់គ្រូបង្រៀន២វេន គ្រូបង្រៀនថ្នាក់គួ និង សំណើសុំទទួលស្គាល់គ្រូបង្រៀននៅតំបន់ជួបការលំបាក។
- បានចូលរួម ការធ្វើតេស្តជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា របស់មន្ទីរអប់រំ យុវជន និងកីឡា សម្រាប់ឆ្នាំ២០១៦-២០១៧ ។

## ១.៣ ការខារត្រួតពិនិត្យរដ្ឋបាល និងបៀវត្ស

- ការប្រែប្រួលស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រីរាជការស៊ីវិលសរុបចំនួន ៥០,១៣២ករណី/សំណុំលិខិត
- មន្ទីរបានធ្វើការពិនិត្យ ផ្ទៀងផ្ទាត់ ផ្តល់យោបល់ ផ្តល់ទិដ្ឋាការលើសំណើសុំនានាពាក់ព័ន្ធនឹងការប្រែប្រួលស្ថានភាពរដ្ឋបាល និងគ្រួសាររបស់មន្ត្រីរាជការស៊ីវិលក្នុង ឆ្នាំ២០១៦ ជូនមន្ទីរជំនាញ និងអង្គភាពនានាជុំវិញខេត្ត បានទាន់ពេលវេលា
- ពិនិត្យផ្ទៀងផ្ទាត់លើតារាងឥណទានបៀវត្សជូនមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា របស់មន្ទីរជំនាញ និងអង្គភាពនានាជុំវិញរាជធានី ខេត្ត
- មន្ទីរមុខងារសាធារណៈ បានចុះពិនិត្យ និងណែនាំដល់មន្ទីរ អង្គភាព ក្រុង ស្រុក ឱ្យបង្វែរថវិការដ្ឋមកវិញ
- បានត្រួតពិនិត្យការប្រែប្រួលស្ថានភាពរដ្ឋបាល និងគ្រួសាររបស់មន្ត្រីរាជការស៊ីវិលរបស់មន្ទីរ និងអង្គភាពនានាសរុបចំនួន ៥០,១៣២ករណី/សំណុំលិខិត។
- មន្ទីរមុខងារសាធារណៈបានចុះពិនិត្យមន្ត្រីរាជការដែលមានមុខតំណែងអចិន្ត្រៃយ៍ លើសពីមួយ និងមន្ត្រីរាជការដែលទទួលបៀវត្សពីរកន្លែងនៅជុំវិញខេត្តមានចំនួន១៣នាក់។

## ២) បញ្ហាប្រឈម

- ការតែងតាំងមន្ត្រីសម្រាប់មុខតំណែងគ្រប់គ្រងថ្នាក់ការិយាល័យនិងអនុការិយាល័យមិនទាន់គ្រប់នៅឡើយ
- មន្ទីរ អង្គភាពនានាក្នុងខេត្តមួយចំនួននៅតែមានភាពយឺតយ៉ាវក្នុងការធ្វើរបាយការណ៍បៀវត្សប្រចាំខែ របាយការណ៍ប្រែប្រួលស្ថានភាពរដ្ឋបាលនិងគ្រួសារមន្ត្រីរាជការ ការធ្វើស្វ័យប្រកាស សម្រេចស្នើសុំប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា និងសំណុំឯកសាររបស់មន្ត្រីជាប់កិច្ចសន្យាមកមន្ទីរមុខងារសាធារណៈ
- មន្ទីរ អង្គភាពមួយចំនួនពុំទាន់ផ្ដល់ឯកសារពាក់ព័ន្ធនឹងការបង្វែរថវិកាចូលរដ្ឋវិញ
- មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត នៅមានកង្វះធនធានមនុស្ស អគាររដ្ឋបាល និងមធ្យោបាយសម្រាប់បំពេញការងារ
- មន្ទីរមុខងារសាធារណៈ នៅមានមន្ត្រីតិច មិនទាន់ឆ្លើយតបនឹងការងារបច្ចុប្បន្ន

## ៣) សំណូមពររបស់មន្ទីរមុខងារសាធារណៈ

- ស្នើសុំឱ្យមានការបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពដល់មន្រ្តីក្នុងមន្ទីរ
- ស្នើសុំផ្ដល់លទ្ធភាពឱ្យមន្រ្តីរបស់មន្ទីរបានចូលរួមវគ្គបណ្ដុះបណ្ដាល សិក្ខាសាលានៅបរទេស ដើម្បីពង្រីកការយល់ដឹង និងបានជាបទពិសោធន៍ល្អសម្រាប់ចែករំលែកក្នុងអង្គភាព
- ស្នើសុំសាងសង់អគាររដ្ឋបាលរបស់មន្ទីរ ដើម្បីសម្រួលដល់ការបំពេញកិច្ចការរបស់មន្ទីរ
- ស្នើសុំឱ្យមានការបណ្ដុះបណ្ដាលពាក់ព័ន្ធនឹងការអនុវត្តថវិកាតាមកម្មវិធី ដើម្បីឱ្យមន្រ្តីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តថវិកាតាមកម្មវិធីនៅឆ្នាំ២០១៧ខាងមុខនេះ

# ៤) ទិសដៅការងារបន្តសម្រាប់ឆ្នាំ២០១៧

- បន្តចុះត្រួតពិនិត្យលើការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា
- ចុះត្រួតពិនិត្យលើការប្រើប្រាស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៅមន្ទីរសុខាភិបាលតាមបណ្តាខេត្តមួយចំនួន
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ
- សហការសម្របសម្រួលការប្រឡងប្រជែងជ្រើសរើសមន្ត្រីក្របខណ្ឌ និងចូលរួមក្នុងដំណើរការជ្រើសរើសប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត តាមបណ្តាមន្ទីរនិងអង្គភាពនានាក្នុងខេត្ត
- បូកសរុបរបាយការណ៍ក្របខ័ណ្ឌ ឥណទាន បៀវត្សមន្ត្រីរាជការស៊ីវិលប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- បន្តពិនិត្យ និងផ្តល់ទិដ្ឋាការឯកសាតារាងទូទាត់បៀវត្សមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ជូនមន្ទីរនានា ជុំវិញខេត្ត
- បន្តពិនិត្យនិងផ្តល់ទិដ្ឋាការរាល់ការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលរបស់សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពនានា
- អនុវត្តការងារផែនការសកម្មផ្សេងៗ ដែលក្រសួងបានផ្តល់ជូន

# សេចក្តីសន្និដ្ឋាន

- មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត បានខិតខំប្រឹងប្រែងបំពេញការងារបានល្អ ដែលធ្វើឱ្យមានការជឿទុកចិត្តនិងគាំទ្រលើស្នាដៃបំពេញការងារពីសំណាក់សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពនានា។

- មានការសហការជាមួយសាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពនានាជុំវិញរាជធានី ខេត្ត។

- សាលារាជធានី ខេត្ត បានទទួលស្គាល់សមត្ថភាពការងារ និងចាត់ទុកមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ជាសេនាធិការនៅក្នុងការគ្រប់គ្រងបុគ្គលិកមិនអាចខ្វះបាន ជាពិសេសលើការតែងតាំង ការផ្ទេរចេញ ផ្ទេរចូល និងការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលផ្សេងៗ។

# សូមអរគុណ!